ព្រះរាជបណ្ណាល័យកម្ពុជា

# KAMBUJASURIYÂ

# កម្ពុជសុរិយា

សៀវភៅទស្សនាវដ្តីចេញផ្សាយរាល់ខែ ពីព្រះរាជបណ្ណាល័យ

ឆ្នាំគំរប់ ១២

ខែ ៩

កុង្សីយ៍សេនាបតីបានអនុញ្ញាតហើយ
សម្ដេចសង្ឃនាយកទាំងពីរគណៈយល់ព្រម

ភ្នំពេញ
ការផ្សាយរបស់ព្រះរាជបណ្ណាល័យ
ព. ស. ២៤៨៣
គ. ស. ១៩៤០

## សេចក្ដីជូនដំណឹង

# អំពីទស្សនាវដ្ដីកម្ពុជសុរិយា

ទស្សនាវដ្ដីកម្ពុជសុរិយានេះ បានចេញផ្សាយរឿងរ៉ាវទាំងគតិលោក គតិធម៌ ដើម្បីចែកជូនដល់ញាតិជាតិខ្មែរមើល ដោយដំឡៃយ៉ាងថោក បំផុតឥតយកចំណេញ សព្វថ្ងៃនេះគិតត្រឹម ១ ឆ្នាំ ៤ រៀលប៉ុណ្ណោះ តែ ដល់ទៅឆ្នាំ ១៩៤១ ទស្សនាវដ្ដីនឹងនៅទ្រាំទ្រតាមដំឡៃដដែលនេះទៀតពុំ បានគោងតែគិតដំឡើងថ្លៃឡើងទៀតខ្លះជា ១ ឆ្នាំ ៦ រៀល ៥០ សេន ចំនួន សៀវភៅ ១២ ក្បាលក្នុង ១ ឆ្នាំ ។ ដំឡៃនេះ គិតត្រឹមតែរួចខ្លួនមិនមែន យកចំណេញទេ ។

អស់លោក-អ្នកគង់ជ្រាបច្បាស់ហើយថា សព្វថ្ងៃនេះមិនថាវត្ថុអ្វីៗ ទេ សុទ្ធតែឡើងថ្លៃគ្រប់ចំពូក ហេតុដល់ក្រដាសសម្រាប់បោះពុម្ពទស្សនា- វដ្ដីនេះក៏ឡើងថ្លៃមួយជាបីជាបួន ថែមទាំងរកទិញបានដោយកម្រផង ។ កាលបើលោក-អ្នកបានជ្រាបសេចក្ដីពិតដូច្នេះហើយ ក៏មិនត្រូវមានចិត្ត ធុញទ្រាន់នឹងដំឡៃដែលត្រូវដំឡើងបន្ថែមបន្តិចបន្តួចនេះទេ ។ មួយវិញ ទៀតបើយើងពិនិត្យមើលរឿងផ្សេងៗ ដែលមានចុះផ្សាយរាល់ខែក្នុងឆ្នាំ ១៩៤០ នេះជាដើមទៅ គង់យល់ថា រឿងនីមួយៗមានដំឡៃថ្លៃខ្ពស់លើសថ្លៃ ជាច្រើនលើសលប់គណនា ដូចពង្សាវតាររបស់នានាប្រទេស ឬពង្សាវតារ លោកដែលយើងចុះផ្សាយរាល់ខែនេះ នាំឲ្យលោក-អ្នកមើលទស្សនាវដ្ដី កើតចំណេះចេះដឹងយ៉ាងធំទូលាយ ហាក់ដូចជាលោក-អ្នកមានអាយុរាប់

តាំងពាន់ៗឆ្នាំ ហើយបានធ្វើដំណើរទៅកាន់នានាប្រទេសដោយខ្លួនឯង ហើយបានដឹងបានឮរឿងរ៉ាវប្លែកៗក្នុងប្រទេសនោះៗយ៉ាងអស្ចារ្យ ។ ចំណែកខាងគតិធម៌វិញ ក៏បានចុះផ្សាយរឿងពុទ្ធសាសនាដែលមានក្នុងនានាប្រទេសដែលកាន់ពុទ្ធសាសនា តាំងអំពីសម័យបុរាណដរាបមកដល់សម័យបច្ចុប្បន្ននេះ ដើម្បីជាគ្រឿងប្រដាប់សតិបញ្ញារបស់ពុទ្ធសាសនិកជនខេមរជាតិ ព្រមទាំងគំនិតយោបល់របស់ពួកអ្នកប្រាជ្ញអឺរ៉ុបដែលនិយាយអំពីពុទ្ធសាសនារបស់យើងនេះផង ។

ហេតុដូច្នេះ អស់លោកដែលចុះឈ្មោះជាវមកហើយគួរតែចុះឈ្មោះជាវក្នុងឆ្នាំមុខតទៅទៀត អស់លោកអ្នកដែលមិនទាន់ចុះឈ្មោះជាវទេ កាលបើបានជ្រាបដំណឹងនេះហើយគួរតែនាំគ្នាមកចុះឈ្មោះជាវឲ្យកាន់តែច្រើនឡើង ហើយជួយផ្សាយដំណឹងនេះតៗគ្នាទៅទៀតផង ដើម្បីជួយជ្រោមជ្រែងអក្សរសាស្ត្រខ្មែរនិងពុទ្ធសាសនាឲ្យបានឋិតថេរ និងចំរើនរុងរឿងនៅក្នុងកំឡុងក្រុងកម្ពុជានេះអស់កាលជាអង្វែងតរៀងទៅ ។

មួយវិញទៀត យើងសូមក្រើនទុកជាមុនថា ដំឡៃជាវទស្សនាវដ្ដីក្នុងឆ្នាំ ១៩៤១ នេះ ជាដំឡៃ ៦ រៀល ៥០ សេនក្នុង ១ ឆ្នាំ នេះមិនមែនកំណត់យកជាដំឡៃស្ថាប់ក្រឡាទេ កាលណាក្រដាសសំបូរធូរថ្លៃគ្រាន់បើ យើងនឹងបន្ថោកថ្លៃទស្សនាវដ្ដីនេះឲ្យចុះថោកទៅវិញ ដោយគិតដំឡៃត្រឹមតែរួចខ្លួនប៉ុណ្ណោះ ។

តាំងពាន់ៗឆ្នាំ ហើយបានធ្វើដំណើរទៅកាន់នានាប្រទេសដោយខ្លួនឯង ហើយបានដឹងបានឮរឿងរ៉ាវប្លែកៗក្នុងប្រទេសនោះៗយ៉ាងអស្ចារ្យ ។ ចំណែកខាងគតិធម៌វិញ ក៏បានចុះផ្សាយរឿងពុទ្ធសាសនាដែលមានក្នុងនានាប្រទេសដែលកាន់ពុទ្ធសាសនា តាំងអំពីសម័យបុរាណដរាបមកដល់សម័យបច្ចុប្បន្ននេះ ដើម្បីជាគ្រឿងប្រដាប់សតិបញ្ញារបស់ពុទ្ធសាសនិកជនខ្មែរជាតិ ព្រមទាំងគំនិតយោបល់របស់ពួកអ្នកប្រាជ្ញទូរូបដែលនិយាយអំពីពុទ្ធសាសនារបស់យើងនេះផង ។

ហេតុដូច្នេះ អស់លោកដែលចុះឈ្មោះជាវមែកហើយគួរតែចុះឈ្មោះជាវក្នុងឆ្នាំមុខតទៅទៀត អស់លោកអ្នកដែលមិនទាន់ចុះឈ្មោះជាវទេ កាលបើបានជ្រាបដំណឹងនេះហើយគួរតែនាំគ្នាមកចុះឈ្មោះជាវឲ្យកាន់តែច្រើនឡើង ហើយជួយផ្សាយដំណឹងនេះតៗគ្នាទៅទៀតផង ដើម្បីជួយជ្រោមជ្រែងអក្សរសាស្ត្រខ្មែរ និងពុទ្ធសាសនាឲ្យបានឋិតថេរ និងចំរើនរុងរឿងនៅក្នុងកំឡុងក្រុងកម្ពុជានេះអស់កាលជាអង្វែងតរៀងទៅ ។

មួយវិញទៀត យើងសូមក្រើនទុកជាមុនថា ដំឡៃជាវទស្សនាវដ្តីក្នុងឆ្នាំ ១៩៨១ នេះ ជាដំឡៃ ៦ រៀល ៥០ សេនក្នុង ១ ឆ្នាំ នេះមិនមែនកំណត់យកជាដំឡៃស្ថាប់ក្រឡាទេ កាលណាក្រដាសសំបូរធូរថ្លៃគ្រាន់បើ យើងនឹងបន្ថោកថ្លៃទស្សនាវដ្តីនេះឲ្យចុះថោកទៅវិញ ដោយគិតដំឡៃត្រឹមតែរួចខ្លួនប៉ុណ្ណោះ ។

# បញ្ជីរឿង


ទំព័រ

១ — អំពីស្តូបរបស់ព្រះបាទធម្មាសោក របស់លោក ប៉ូល-មុស . . . . . . . . . ៣

២ — ពង្សាវតារសង្ខេបនៃប្រទេសហ្វេនីស៊ាង អ្នកមហាថែមស្រង់យកនឹងប្រែចេញ ពីពង្សាវតារសាកលថៃ របស់ហ្លួងវិចិត្រវាទការ . . . . . . . . . . . . ៩

៣ — អំពីយោបល់របស់លោកអល្ប៊ែរស្មេតសែរ ថ្លែងអំពីពុទ្ធសាសនា . . . . . . . ១៥

៤ — អំពីពុទ្ធសាសនានៅប្រទេសជប៉ុន តាមសៀវភៅលោកតូមោម៉ុតស៊ុ . . . . . ២៥

៥ — ពុទ្ធប្បវត្តិ តាមគំនូររបស់ចិន (តមក) . . . . . . . . . . . . . . . ៤១

៦ — ប្រវត្តិមីលរេប៉ៈ ប្រែចេញពីភាសាទីបេតាំងមកជាបារាំងសែស របស់លោកស៊ុកបាកូត៍ (នៅមានត) . . . . . . . . . . . . . . . . . . ៤៥

៧ — ដំណឹងផ្សេងៗ . . . . . . . . . . . . . . . . . . . . . . . ៤៧

៨ — ប្រជុំពាក្យកាព្យខ្មែរ ភាគទី ៤ របស់រក្សកិរម្យ អួង (ត) . . . . . . . . . ៤១


## រូបក្រៅរឿង


តាមបែបគំនូរចិន

១ — អំពីព្រះរាហុលកុមារចេញបួស . . . . . . . . . . . . . . ១

២ — អំពីសុទត្តសេដ្ឋីក្រាបបង្គំទូលអារាធនា . . . . . . . . . ៧

៣ — អំពីការចំណាយទ្រព្យទិញសួនជេតវន . . . . . . . . . . ១៣

៤ — អំពីការទ្រង់ផ្លាស់ចិត្តគំនិតរបស់ពួកអ្នកនេសាទត្រី . . . . . ២៣

៥ — អំពីការទ្រង់ផ្ចាញ់ផ្ចាលហ្លួងដំរីបុះប្រេង . . . . . . . . . ៣៩

គំនូរទីបេតាំង

៦ — លោកមីលរេប៉ៈហោះឡើងទៅលើអាកាស. . . . . . . . . ៤៣

# TABLE DES MATIÈRES


Pages

1° Les Stûpas d'Açoka d'après une étude de Paul-Mus...... 3

2° Histoire sommaire des Phéniciens, extrait de l'histoire générale thailandaise par Luong VICHITRAVADAKARN, traduit en Cambodgien par MAHA NHUK THÊM.................... 9

3° Remarques d'Albert Schweitzer sur le Bouddhisme......... 15

4° Le Bouddhisme au Japon, extraits du livre de Monsieur TOMOMATSU (suite)........................... 25

5° La Vie du Bouddha d'après des documents chinois (suite). 41

6° La Vie de Milarépa, traduit du Tibétain en Français par JACQUES BACOT (suite)........................... 45

7° Informations diverses.............................. 47

8° Recueil de Poèmes Cambodgiens; 4° partie, par RAK-PHIROM UONG (suite)....................................... 51

HORS TEXTES:

Dessins chinois....

1° départ de Rahula.................. 1

2° La requête de Sudatta.............. 7

3° L'achat du JETAVANA............... 13

4° Conversion des pêcheurs........... 23

5° Le BOUDDHA maîtrise les éléphants furieux........................ 39

Peinture tibétaine.. 6° Milarépa volant à travers l'espace... 43



៣០ — អំពីព្រះរាហុលកុមារចេញបួស

# អំពីព្រះស្តូបរបស់ព្រះបាទធម្មាសោក

លោក ប៉ូល មុស (Paul Mus) ទើបនឹងរៀបរៀងរឿងមួយដូចមានឈ្មោះខាងលើនេះ ។ លោកនេះជាអ្នកយកចិត្តទុកដាក់សិក្សាព្រះពុទ្ធ-សាសនាតាមពង្សាវតារសាសនានិងអក្សាត្ថវិទ្យា បានពោលតាមសេចក្ដីកត់ហេតុដែលលោកសង្ឃចិនឈ្មោះ ហ្វួន-ត្សង្គ (Hiuan-Tsang) ធ្វើដំ-ណើរទៅស្រុកឥណ្ឌា កាលពីពុទ្ធសករាជ ១១៨០ នោះមានសេចក្ដីដំណាលពីស្តូបដែលលោកបានឃើញថា ស្តូបអស់នេះកសាងឡើងក្នុងរជ្ជកាល ព្រះបាទអសោកមហាធម្មិករាជដែលមានព្រះកិត្តិសព្ទល្បីល្បាញ ទ្រង់បានឲ្យឆ្លាក់ចារិកព្រះរាជប្រកាសនិងសសរគោលជាច្រើន ក្នុងព្រះរាជអាណាចក្ររបស់ទ្រង់ ។ ចុះហេតុអ្វីបានជាគេថា ស្តូបអស់នេះជារបស់ស្ដេចអសោក ? លោក ហ្វួន-ត្សង្គ បានកត់ត្រាទុកថា ស្តូបអស់នេះខ្លប ខាតលិចចុះទៅក្នុងដីហើយ ជាគេមើលឃើញតែត្រឹមកំពូលស្តូបទ្រង់-ទ្រាយដូចជាតានប៉ុណ្ណោះ ។ គេជឿថាមានអនុស្សាវរីយខ្លះដែលកប់លិចបាត់ទៅក្នុងដី ។

នៅប្រាសាទអង្គរយើង សព្វថ្ងៃនេះគេក៏បានសើរើគាស់កកាយយកដីចេញរហូតទៅដល់បាតប្រាសាទបុរេចេតិយ ប៉ុន្តែស្តូបអសោកអស់នេះ ដែលលោកសង្ឃចិនជាអ្នកធុតង្គដំណាលប្រាប់ មិនមែនកប់បាត់ទៅក្នុងដី

តាមដែលជឿនោះទេ ដែលគេដឹងបានក្នុងវេលានេះ ដោយសារថ្មីដែលពួក-អ្នកប្រាជ្ញដែលខំសើរើករក ទើបដឹងថាស្តូបបុរាណអស់នេះមានគ្រឿងកំ-ពូលជូន់ ថែមទាំងមិនបានបោះបូសនៅបាតស្តូបផង ។ សូម្បីក្នុងខណៈដែលស្តូបមិនទាន់ចាស់គ្រាំគ្រា ប៉ុន្តែមានកំពស់ខ្ពស់ពេកថែមទាំងមានសណ្ឋានដូចបញ្ចុកផង (គឺគ្រឿងក្រោមមិនស្មើមាំមួនចំណាប់ ទ្រគ្រឿងលើមិនបាន ) មានទំនងដូចជាស្តូបឬចេតិយគេកសាងឡើងក្នុងសម័យសព្វថ្ងៃនេះ ដែលមាននៅក្នុងស្រុកភូមា ស្រុកខ្មែរ ស្រុកចិនទីង ស្រុកសៀម ។

សេចក្ដីសំខាន់ដែលលោក ប៉ូល-មូស ពន្យល់នោះថា ហេតុអ្វីបានជាលោកហ្វូន-ត្រគ ជឿថាស្តូបរបស់ស្តេចអសោក "កប់ក្នុងដី" លិចចុះទៅក្នុងដី ? ក្នុងរឿងក៏របស់លោកពុតគ្គដែលធ្វើដំណើរទៅស្រុកឥណ្ឌាទីង សេចក្ដីអធិប្បាយពន្យល់ក្រោយលោកនេះមកនោះថា ប្រសិនបើចេតិយអស់នេះកប់លិចទៅក្នុងដី បានសេចក្ដីថា ស្នាមគន្លងជាគ្រឿងកត់សំគាល់នៃធម៌វិន័យនេះក៏រមែងតែរលុបទៅដែរ ។ លោកប៉ូល-មុស បានប្រែរឿងក៏របស់លោក ហ្វូន-ត្រគ ចេញពីភាសាចិន ទើបឃើញគំនិតដែលពោលពន្យល់យ៉ាងច្បាស់លាស់ដូច្នេះ:

តាំងអំពីពិភពលោកចូលមកកាន់យុគឬកប្បដែលកន្លងមកហើយនេះ ច្បាប់ដែលត្រឹមត្រូវកាន់តែទន់ខ្សោយទៅបន្តិចម្តងៗ ខ្សាច់នឹងដីក៏ដុះចំរើន

តាមដែលជឿនោះទេ ដែលគេដឹងបានក្នុងវេលានេះ ដោយសារថ្មីដែលពួកអ្នកប្រាជ្ញដែលខំសើរើកវែក ទើបដឹងថាស្តូបបុរាណអស់នេះមានគ្រឿងកំពូលធ្ងន់ ថែមទាំងមិនបានបោះបួសនៅបាតស្តូបផង ៗ សូម្បីក្នុងខណៈដែលស្តូបមិនទាន់ចាស់គ្រាំគ្រា ប៉ុន្តែមានកំពស់ខ្ពស់ពេកថែមទាំងមានសណ្ឋានដូចបញ្ចុះផង (គឺគ្រឿងក្រោមមិនសូវមាំមួនចំណាប់ ទ្រគ្រឿងលើមិនបាន ) មានទំនងដូចជាស្តូបឬចេតិយគេកសាងឡើងក្នុងសម័យសព្វថ្ងៃនេះ ដែលមាននៅក្នុងស្រុកភូមា ស្រុកខ្មែរ ស្រុកចិននឹងស្រុកសៀម ៗ

សេចក្តីសំខាន់ដែលលោក ប៉ូល-មូស ពន្យល់នោះថា ហេតុអ្វីបានជាលោកហ្វូន-ត្សង្គ ជឿថាស្តូបរបស់ស្តេចអសោក "កប់ក្នុងដី" លិចចុះទៅក្នុងដី ? ក្នុងរឿងការរបស់លោកពុតគ្គដែលធ្វើដំណើរទៅស្រុកឥណ្ឌានឹងសេចក្តីអធិប្បាយពន្យល់ក្រោយលោកនេះមកនោះថា ប្រសិនបើចេតិយអស់នេះកប់លិចទៅក្នុងដី បានសេចក្តីថា ស្នាមគន្លងជាគ្រឿងកត់សំគាល់នៃធម៌វិន័យនេះក៏រមែងតែរលុបទៅដែរ ៗ លោកប៉ូល-មុស បានប្រែរឿងការរបស់លោក ហ្វូន-ត្សង្គ ចេញពីភាសាចិន ទើបឃើញគំនិតដែលពោលពន្យល់យ៉ាងច្បាស់លាស់ដូច្នេះ :

តាំងអំពីពិភពលោកចូលមកកាន់យុគឬកប្បដែលកន្លងមកហើយនេះច្បាប់ដែលត្រឹមត្រូវកាន់តែទន់ខ្សោយទៅបន្តិចម្តងៗ ខ្សាច់នឹងដីក៏ដុះចំរើន

ឡើងគ្របបល្ល័ង្កពេជ្រអស់ទៅ ឥតនរណាមើលឃើញឡើយ ។ តាំងអំពីក្រោយព្រះពុទ្ធបរិនិព្វានមក បណ្ដាស្ដេចនៃប្រទេសទាំងពួងបានជ្រួតជ្រាបប្រវេណីទីងខ្នាតទំហំនៃបល្ល័ង្កពេជ្រនោះ តាមសេចក្ដីដែលព្រះពុទ្ធជាម្ចាស់ទ្រង់សំដែងទុកមក មានកំណត់ព្រំប្រទល់ពីទិសខាងត្បូងទៅទិសខាងជើង ដោយមានរូបពោធិសត្វអវលោកិតេស្វរៈពីរអង្គទ្រង់គង់នៅចាំហៀងទិសខាងកើត ។ មនុស្សចាស់ៗ តែងដំណាលអំពីរឿងនេះថា កាលតួអង្គពោធិសត្វកប់លិចនៅក្នុងដី ហើយមើលមិនឃើញតទៅទៀតក្នុងកាលណា ច្បាប់ព្រះធម៌របស់ព្រះពុទ្ធជាម្ចាស់ត្រូវតែរលត់បាត់ទៅក្នុងកាលនោះដែរ ។

ឥឡូវនេះ រូបពោធិសត្វនៅជ្រុងទិសខាងត្បូង បានរលុបកប់បាត់ទៅក្នុងដីសល់នៅត្រឹមព្រះឧរៈ (ទ្រូង) ។ ទំនៀមទម្លាប់នៃការសាបសូន្យព្រះសទ្ធម្មនេះឯងទើបមានប្រាកដនៅក្នុងក្បួនរបស់អ្នកធុតង្គចិន ប៉ុន្តែឯរឿងរ៉ាវព្រះស្តូបមានសេចក្ដីដំណាលទុកមកដូច្នេះ គេនិយាយថា កាលណាព្រះស្តូបអស់នេះកប់លិចបាត់ទៅក្នុងដី សាសនារបស់ព្រះពុទ្ធក៏នឹងវិនាសបាត់ទៅដែរ ។

លោក ប៉ូល-មុស បញ្ចប់យោបល់របស់លោកតាមសេចក្ដីកត់ហេតុដែលលោកហ្វួន-ត្សង់ និងលោកធុតង្គចិនឯទៀតៗ ពោលអំពីចេតិយព្រះពុទ្ធនៅប្រទេសឥណ្ឌាថា សុទ្ធតែកប់នៅក្នុងដី ហើយលោកអស់នេះមិន

យល់មិនពិចារណាទៅតាមហេតុកើតធម្មតាក្នុងសតវត្សរ៍នីមួយៗ នឹងការដុះដាលចំរើនឡើងនៃផែនដី នឹងហេតុដែលចាប់កសាងព្រះស្តូបអស់នេះមានបែបភាពផ្សេងៗគ្នានោះទេ (គឺមិនទឹកនាំអំពីហេតុកើតអស់នេះឡើយ) មើលឃើញតែរបស់មួយយ៉ាង គឺគំនូសនៃច្បាប់ឥតទរណាចៀសវាងបាន លុះលោកដល់នូវសេចក្តីវិនាសទៅ ក្នុងទីបំផុតនៃកាលវេលា មុនព្រះស្រីអរិយមេត្រីជាពុទ្ធអនាគតមកជួយស្រោចស្រង់នោះ គោលចារិកនៃព្រះធម៌នឹងវិនាសទៅព្រមទាំងដឹកនាំរបស់ឯទៀតៗ ឲ្យវិនាសទៅជាមួយគ្នាផង ។

ដោយហេតុបណ្តាពុទ្ធសាសនិកជាតិចិន បណ្តាពួកមនុស្សក្នុងសម័យនោះបានយកចិត្តទុកដាក់តែខាងចិត្តវិជ្ជា ដែលនាំឲ្យកើតគំនិតនឹងសតិបញ្ញាប៉ុណ្ណោះ ច្រើនជាងសេចក្តីកង្វល់វិតក្កអំពីរឿងស្តូបចេតិយ ទើបលោកបានសរសេរសេចក្តីព្យាការរបស់លោកទុកដូចបានពោលមកនេះ ។

យល់មិនពិចារណាទៅតាមហេតុកើតធម្មតាក្នុងសតវត្សរ៍នីមួយៗ នឹងការដុះដាលចំរើនឡើងនៃផែនដី នឹងហេតុដែលចាប់កសាងព្រះស្តូបអស់នេះ មានបែបភាពផ្សេងៗគ្នានោះទេ (គឺមិនទឹកនាំអំពីហេតុកើតអស់នេះឡើយ) មើលឃើញតែរបស់មួយយ៉ាង គឺគំនូសនៃច្បាប់ឥតនរណាចៀសវាងបាន លុះលោកដល់នូវសេចក្តីវិនាសទៅ ក្នុងទីបំផុតនៃកាលវេលា មុនព្រះស្រីអរិយមេត្រីជាពុទ្ធអនាគតមកជួយស្រោចស្រង់នោះ គោលចារិកនៃព្រះធម៌នឹងវិនាសទៅព្រមទាំងដឹកនាំរបស់ឯទៀតៗ ឲ្យវិនាសទៅជាមួយគ្នាផង ។

ដោយហេតុបណ្តាពុទ្ធសាសនិកជាតិចិន បណ្តាពួកមនុស្សក្នុងសម័យនោះបានយកចិត្តទុកដាក់តែខាងចិត្តវិជ្ជា ដែលនាំឲ្យកើតគំនិតនឹងសតិបញ្ញាប៉ុណ្ណោះ ច្រើនជាងសេចក្តីកង្វល់វិតក្កអំពីរឿងស្តូបចេតិយ ទើបលោកបានសរសេរសេចក្តីពយការរបស់លោកទុកដូចបានពោលមកនេះ ។



៣១ — អំពីសុទត្តសេដ្ឋីក្រាបបង្គំទូលអារាធនា ។

# ពង្សាវតារសង្ខេប

របស់

# ជាតិហ្វេនីស៊ាំង

(Phenicien)

ជនជាតិនេះ អ្នកតែងពង្សាវតារលោកតែងតែរម្លងពេលដោយច្រើន ព្រោះហេតុជាជាតិតូចម៉្យាង ហើយម៉្យាងទៀត ជនជាតិនេះមិនបានកសាងសេចក្ដីចំរើនឯណាទីមួយ ឲ្យឃើញប្រាកដច្បាស់ទុកមកដល់សព្វថ្ងៃនេះ តែទុកជាដូចម្ដេចក៏ដោយ ជនជាតិនេះក៏គួររាប់ថាជាជនជាតិសំខាន់ណាស់ដែរក្នុងសម័យបុរាណ ប្រសិនបើយើងមិនសិក្សាឲ្យដឹងខ្លះសោះនោះ ចំណេះប្រវត្តិសាស្ត្រក៏ខ្វះខាតត្រង់កន្លែងសំខាន់នេះមិនខាន ។

ពួកហ្វេនីស៊ាំង មានពូជអំបូរជាប់តមកអំពីពួកសេមីទិក ហើយចេញមកអំពីប្រទេសសាលដេដូចពួកហេប្រឺដែរ មានការគោរពរាប់អានព្រះដែលជាគ្រឿងសន្មតជំនួសព្រះអាទិត្យព្រះចន្ទ្រ មានទំនងដូចពួកអេស៊ីប្ដ៍និងសាលដេ មានស្រុកទេសជាប់គ្នានឹងពួកហេប្រឺ តែនៅមាត់សមុទ្រ ។ ដំបូងតាំងក្រុងនៅស្រុកស៊ីដុង (Sidon) ដល់ក្រោយមកតាំង

ក្រុងនៅស្រុកទីរ (Tyr) ជនពួកនេះជាអ្នកដើរសមុទ្រ ទឹងបេះធ្វើជំនួញមកមុខៗជាតិដទៃៗទាំងអស់ក្នុងលោក ឯថ្វីដៃជាងក៏មិនចាញ់ជាតិអេស៊ីប្ត៍ដែរ ក្រុងហ្យេរុយសាលេមរបស់ជាតិហេប្រឺនោះ ក៏កសាងសម្រេចដោយថ្វីដៃរបស់ពួកហ្វេនីស៊ាំងនេះដែរ ។ ជនពួកនេះបានធ្វើដំណើរតាមទូកទៅលក់ដូរក្នុងប្រទេសផ្សេងៗ ហើយជាជនជាតិដំបូងដែលបេះរកវិធីដួលទីដីក្នុងស្រុកតាំងប្រទេសដើម្បីតាំងទីកន្លែងលក់ដូររបស់ខ្លួន ដែលជាគំនិតដើមនៃរបៀបសម្បទាន (Concession) ដែលជនជាតិឱរុបកំពុងធ្វើជាមួយនឹងចិនដោយអន្លើដូចនៅហុងកុងនឹងជាងស៊ុនជាដើម ។ តែរបស់ដែលចំឡែកប្លែកច្រើន ក៏គឺជាតិហ្វេនីស៊ាំងជាជាតិតូចៗទាំងមិនមានល្បីថាមានជាជាតិមានថ្វីដៃក្នុងការបម្រាំងផង ក៏នៅតែអាចទៅដួលទីដីនឹងតាំងកន្លែងធ្វើការជំនួញបានជាច្រើនអន្លើ ដូចនៅតាមកោះសំខាន់ផ្សេងៗក្នុងសមុទ្រមេឌីទែរ៉ាណេ រហូតដល់ទៅមាត់សមុទ្រអេស្ប៉ាញ៉ុល ។ នៅប្រទេសអេស៊ីប្ត៍ក៏បានចូលទៅតាំងកន្លែងលក់ដូរក្នុងស្រុកសំខាន់ៗ ដូចស្រុកម៉ែមហ្វិសជាដើម ។ តាមមាត់សមុទ្រទ្វីបអាហ្វ្រិក ក៏រើសរកទីដីបានធំវែងដល់ទៅ ១៨០០ គីឡូម៉ែត្រ ដែលជាស្រុកចំណុះនៅក្រោមអំណាចសេចក្តីត្រួតត្រារបស់ខ្លួន ។

បើពោលតាមពិតទៅ យើងនឹងឃើញថាក្នុងសម័យនេះក្តី ក្នុងសម័យបុរាណមកហើយក្តីគំឡាំងអាវុធជារបស់សំខាន់បំផុតក្នុងការផ្សាយ.

ក្រុងនៅស្រុកទីរ (Tyr) ជនពួកនេះជាអ្នកដើរសមុទ្រ ទើបចេះធ្វើជំនួញមកមុខៗជាតិដទៃៗទាំងអស់ក្នុងលោក ឯថ្វីដៃជាងក៏មិនចាញ់ជាតិអេស៊ីប្តិ៍ដែរ ក្រុងហ្សេរុយសាលេមរបស់ជាតិហេប្រឺនោះ ក៏កសាងសម្រេចដោយថ្វីដៃរបស់ពួកហ្វេនីស៊ាននេះដែរ ។ ជនពួកនេះបានធ្វើដំណើរតាមទូកទៅលក់ដូរក្នុងប្រទេសផ្សេងៗ ហើយជាជនជាតិដំបូងដែលចេះរកវិធីជួលទីដីក្នុងស្រុកតាំងប្រទេសដើម្បីតាំងទីកន្លែងលក់ដូររបស់ខ្លួន ដែលជាគំនិតដើមនៃរបៀបសម្បទាន (Concession) ដែលជនជាតិឧរុបកំពុងធ្វើជាមួយនឹងចិនដោយអន្ទើដូចនៅហុងកុងនឹងជាងស៊ុនជាដើម ។ តែរបស់ដែលចំឡែកប្លែកច្រើន ក៏គឺជាតិហ្វេនីស៊ានជាជាតិតូចៗទាំងមិនមានល្បីថាមានជាជាតិមានថ្វីដៃក្នុងការចម្បាំងផង ក៏នៅតែអាចទៅជួលទីដីនឹងតាំងកន្លែងធ្វើការជំនួញបានជាច្រើនអន្ទើ ដូចនៅតាមកោះសំខាន់ផ្សេងៗក្នុងសមុទ្រមេឌីទែរ៉ាណេរ រហូតដល់ទៅមាត់សមុទ្រអេស្ប៉ាញ៉ុល ។ នៅប្រទេសអេស៊ីប្តិ៍ក៏បានចូលទៅតាំងកន្លែងលក់ដូរក្នុងស្រុកសំខាន់ៗ ដូចស្រុកម៉មហ្វិសជាដើម ។ តាមមាត់សមុទ្រទ្វីបអាហ្វ្រិក ក៏រើសរកទីដីបានធំវែងដល់ទៅ ១៥០០ គីឡូម៉ែត្រ ដែលជាស្រុកចំណុះនៅក្រោមអំណាចសេចក្តីត្រួតត្រារបស់ខ្លួន ។

បើពោលតាមពិតទៅ យើងនឹងឃើញថាក្នុងសម័យនេះក្តី ក្នុងសម័យបុរាណមកហើយក្តីកំឡាំងអាវុធជារបស់សំខាន់បំផុតក្នុងការផ្សាយ.

អំណាច ឬជាគ្រឿងរក្សាឥស្សរភាពរបស់ប្រទេសខ្លួន ៗ ជនជាតិហ្វេនីស៊ានជាពួកស្តុកស្តម្ភបរិបូណ៌ដោយទ្រព្យសម្បត្តិ ទាំងមានចំណេះវិជ្ជាបរិបូណ៌ តែខ្វះកំឡាំងកងទ័ពសម្រាប់រក្សាជាតិរបស់ខ្លួន បានជាត្រូវគេញាំញីរហូតមកទាំងត្រូវនៅក្រោមអំណាចរបស់អេស៊ីព្ទ ផុតពីអេស៊ីព្ទក៏ធ្លាក់មកនៅក្នុងអំណាចអស្ស៊ីរី ៗ លុះស្រុកទីរបានតាំងជាទីក្រុង ពួកនេះនាំគ្នាបះបោរឡើងតទល់នឹងអស្ស៊ីរី គួរបាត់ជាគ្រាដំបូងដែលជនជាតិហ្វេនីស៊ានគិតប្រឆាំងតទល់នឹងជនជាតិដទៃ តែនៅទីបំផុតទ្រាំទប់ទល់នឹងកំឡាំងរបស់អស្ស៊ីរីមិនបាន ក៏បរាជ័យចាញ់វិនាសអស់ទៅ ហើយផ្លូវដំនួញខាងសមុទ្រក៏ធ្លាក់ទៅនៅក្នុងកណ្ដាប់ដៃរបស់ពួកការតាស៍(Carthage) ក្នុងជាន់ដើមជាស្រុកដែលពួកហ្វេនីស៊ានបាត់តាំងឡើង តែដល់វេលាក្រោយធ្លាក់ទៅក្នុងអំណាចរបស់ប្រទេសប៉ែរ្ស៍, ក្រិក, រោម, ហើយនៅទីបំផុតបានមកជារបស់ទួរគី ៗ

ចប់



៣២– អំពីការបំណាយទ្រព្យទិញសុខដើតវែ

# អំពីលោកអល្បែរស្វេតសែរ

(ALBERT SEHWEITZER)

នេះជាឈ្មោះអ្នកប្រាជ្ញបារាំងសែសម្នាក់ដែលខំប្រឹងប្រែងធ្វើសេចក្តីចំរើនដើម្បីអ្នកដទៃ ហើយលោកព្យាយាមដោះទុក្ខលំបាកវេទនាដោយការព្យាបាលជម្ងឺជនជាតិស្រុកឆ្ងាយ នៅទ្វីបអាហ្វ្រិកនៅត្រង់កន្លែងដែលឥតមានអនាម័យ ហើយលំបាកទឹងចូលទៅដល់មន្ទីរដែលលោកបានសាងឡើងនោះផង ហើយលោកខំធ្វើការនៅទីនោះជាវេលាជាង ២៥ ឆ្នាំ ។

លោកអល្បែរស្វេតសែរ មុនដែលលោកនឹងបានធ្វើជាគ្រូពេទ្យដែលល្បីឈ្មោះនៅក្នុងទ្វីបអឺរ៉ុបនិងអាមេរិកនោះ លោកធ្វើជាមេភ្លេងមួយធំបាន លេងភ្លេងសាសនាយ៉ាងពីរោះ ។ លោកបានតែងសៀវភៅជាច្រើនដែលមាននិយាយពីអ្នកប្រាជ្ញភ្លេងខាងសាសនា ។ ក្រៅពីនេះ លោកបានខំពិនិត្យពិចារណាយ៉ាងម៉ឺងម៉ាត់ពីផ្លូវបរមត្ថវិជ្ជា ហើយលោកបានទទួលប្រកាសនីយបត្រយ៉ាងខ្ពង់ខ្ពស់អំពីមហាវិទ្យាល័យ គឺបានទទួលងារជាដុកទ័រខាងបរមត្ថវិជ្ជានិងខាងសាសនា ។

អ្នកមើលទស្សនាវដ្តីគង់គិតថា ចុះហេតុអ្វីបានជាយើងនិយាយពីលោកអល្បែរស្វេតសែរ? ហើយលោកនេះមានប្រយោជន៍អ្វីដល់ស្រុកខ្មែរនិងពុទ្ធសាសនា? លោកអល្បែរស្វេតសែរនេះពិតមែនតែលោកមានកិច្ចការ:

ដ៏ធ្ងន់ខាងធ្វើគ្រូពេទ្យ ក្នុងប្រទេសដែលមានអាកាសក្តៅអាក្រក់ ហើយប្រទេសនោះមិនមានផ្លូវថ្នល់នឹងភ្លើងអគ្គិសនី នឹងលំបាករកស្បៀងអាហារមិនមែនរកបានងាយស្រួលដូចស្រុកអាយនេះទេ ថែមទាំងនៅឆ្ងាយពីនគរបារាំងសែសជាងប្រទេសឥណ្ឌូស៊ីននេះទៅទៀត ទុកជាដូចម្តេចក៏ដោយលោកនៅមានពេលសរសេរសៀវភៅបានទៀត ដូចជាសៀវភៅមហាបុរសជាសៀវភៅដែលនិយាយពីអ្នកប្រាជ្ញខាងផ្លូវចិត្ត បានផ្សាយគំនិតរបស់ខ្លួនគ្រប់លើប្រជាជនជាចំនួនច្រើន ក្នុងសៀវភៅរបស់លោកនោះហៅថា "មហាមុនីនៃប្រទេសឥណ្ឌា (Les grands penseurs de l'Inde)" ក្នុងចំណែកមួយនៃសៀវភៅនោះ និយាយសុទ្ធតែពីព្រះពុទ្ធសាសនា ។ យើងនឹងដកស្រង់យកមកដើម្បីអ្នកមើលទស្សនាវដ្តីរបស់យើង ។ សូមបង្ហាញឈ្មោះអ្នកតែងសៀវភៅនេះ ថាជាអ្នកប្រាជ្ញបារាំងសែសមួយក្នុងសម័យយើងសព្វថ្ងៃនេះ ។ ឯប្រយោជន៍នៃសៀវភៅរបស់លោកអែល្បែរស្វេតសែរនេះ គឺលោកបានប្រៀបធៀបលទ្ធិពុទ្ធសាសនានឹងលទ្ធិសាសនាក្រេបៀង ហើយចង្អុលឲ្យឃើញសេចក្តីដែលប្លែកផ្សេងពីគ្នា ឲ្យឃើញសេចក្តីប៉ុនប៉ងសំខាន់ៗ មានទំនងត្រូវគ្នាសព្វគ្រប់ ដើម្បីបង្ហាញព្រះពុទ្ធសាសនាដល់ពួកឱរុប ដែលលោកយល់ថាមិនមែនជាសាសនាប្លែកពីគ្នាប៉ុន្មានទេ លោកបានពន្យល់ឲ្យចូលចិត្តស្តាប់បានតាមគំនិតយោបល់របស់ឱរុបសព្វថ្ងៃនេះ ។

ដ៏ធ្ងន់ខាងធ្វើគ្រូពេទ្យ ក្នុងប្រទេសដែលមានអាកាសក្តៅអាក្រក់ ហើយ
ប្រទេសនោះមិនមានផ្លូវថ្នល់នឹងភ្លើងអគ្គិសនី នឹងលំបាករកស្បៀងអាហារ
មិនមែនរកបានងាយស្រួលដូចស្រុកអាយនេះទេ ថែមទាំងនៅឆ្ងាយពីនគរ
បារាំងសែសជាងប្រទេសឥណ្ឌូស៊ីននេះទៅទៀត ទុកជាដូចម្តេចក៏ដោយ
លោកនៅមានពេលសរសេរសៀវភៅបានទៀត ដូចជាសៀវភៅមហា-
បុរសជាសៀវភៅដែលនិយាយពីអ្នកប្រាជ្ញខាងផ្លូវចិត្ត បានផ្សាយគំនិត
របស់ខ្លួនគ្របលើប្រជាជនជាចំនួនច្រើន ក្នុងសៀវភៅរបស់លោកនោះ
ហៅថា "មហាមុនីនៃប្រទេសឥណ្ឌា (Les grands penseurs de l'Inde)"
ក្នុងចំណែកមួយនៃសៀវភៅនោះ និយាយសុទ្ធតែពីព្រះពុទ្ធសាសនា ។
យើងនឹងដកស្រង់យកមកដើម្បីអ្នកមើលទស្សនាវដ្តីរបស់យើងៗសូម
បង្ហាញឈ្មោះអ្នកតែងសៀវភៅនេះ ថាជាអ្នកប្រាជ្ញបារាំងសែសមួយក្នុង
សម័យយើងសព្វថ្ងៃនេះ ។ ឯប្រយោជន៍នៃសៀវភៅរបស់លោកអល្បែរ
ស្វេតសែរនេះ គឺលោកបានប្រៀបធៀបលទ្ធិពុទ្ធសាសនានឹងលទ្ធិសាស-
នាគ្រិចៀង ហើយបង្អួលឲ្យឃើញសេចក្តីដែលប្លែកផ្សេងពីគ្នា ឲ្យឃើញ
សេចក្តីប៉ុនប៉ងសំខាន់ៗ មានទំនងត្រូវគ្នាសព្វគ្រប់ ដើម្បីបង្ហាញព្រះ
ពុទ្ធសាសនាដល់ពួកឧរុប ដែលលោកយល់ថាមិនមែនជាសាសនាប្លែក
ពីគ្នាប៉ុន្មានទេ លោកបានពន្យល់ឲ្យចូលចិត្តស្គាប់បានតាមគំនិតយោបល់
របស់ឧរុបសព្វថ្ងៃនេះ ។

មុនដំបូងបង្អស់ លោកបង្ហាញឲ្យឃើញការដំបំឡែករបស់ពុទ្ធសាសនាដែលលះបង់លទ្ធិរបស់តាបស ទាំងវិធីធ្វើទុក្ករកិរិយា ហោល ព្រមទាំងការធ្វើជីវិតឲ្យសប្បាយរីករាយហួសហេតុ ។ ព្រះពុទ្ធទ្រង់លើកយកសេចក្ដីដឹងខ្លួនដោយធម្មជាតិមកធ្វើជាកិច្ចធំបំផុតសំរាប់ព្រះអង្គ ។

ព្រះពុទ្ធនោះមិនមែនជាព្រះដ៏ខ្ពង់ខ្ពស់ (ម្ចាស់សួគ៌) ទេ តែទ្រង់ទទួលថាមានពួកទេវតាដែរ ប៉ុន្តែពួកទេវតាអស់នោះមិនអាចឲ្យគុណទោសអ្វីដល់មនុស្សលោកៗ វិញសោតក៏មិនបាច់ប្រាស្រ័យគ្នាទៅវិញទៅមកកាន់ទេវតាអស់នោះដែរ ។

កិច្ចដែលព្រះពុទ្ធទ្រង់ប្រកាសផ្សាយចេញនោះ គឺទ្រង់ដឹកនាំប្រជាជនឲ្យដកខ្លួនចេញពីការប្រកាន់គ្រោះថ្នាក់យ៉ាងស្មានទៗ នោះចេញហើយ ព្រះអង្គទ្រង់លះបង់គម្ពីរដីការបស់ព្រាហ្មណ៍ (ត្រង់ដែលចាត់មនុស្សជា ៤ វណ្ណៈ) ដោយព្រះអង្គទ្រង់អនុញ្ញាតឲ្យពួកសូទ្រៈដែលជាវណ្ណៈនៅចុងគេបង្អស់នោះមកចូលបួសក្នុងសាសនារបស់ព្រះអង្គបាន ។ កិច្ចការដ៏សំខាន់របស់ព្រះពុទ្ធនោះ នៅត្រង់ដែលទូន្មានចិត្តឲ្យលះបង់លោភ ទោស ដោយវិធីធ្វើចិត្តឲ្យជាប់នៅនឹងសីលធម៌ ឯធម៌នេះក៏មាននៅក្នុងលទ្ធិសាសនាជេនៈ ដែលព្រះពុទ្ធទ្រង់ប្រទះឃើញសេចក្ដីបញ្ញត្តិពីអហឹសា (សេចក្ដីមិនបៀតបៀនគ្នា) នោះ ទុកជាដូចម្ដេចក៏ដោយព្រះពុទ្ធ

ក៏ឈ្មោះថាជាអ្នកបង្កើតសីលធម៌. ប្រកបដោយមេត្តាករុណា (ជាដំបូង) ព្រះអង្គទ្រង់បញ្ញត្តឲ្យប្រៀសវាងសេចក្ដីប្រព្រឹត្តឥតមេត្តាចិត្តចេញ ប៉ុន្តែ មេត្តាចិត្តរបស់ព្រះអង្គជាមេត្តាប្រកបដោយហេតុផល មិនមែនចេះតែ មេត្តាទៅដោយឥតគំនិតនុះទេ ។ ឯការធ្វើសមាធិនោះ ព្រះពុទ្ធទ្រង់ធ្វើ ដែរ ដើម្បីហ្វឹកហ្វឺនដួងចិត្តឲ្យប្រព្រឹត្តទៅតាមធម្មជាតិសីលធម៌ ។

ព្រះពុទ្ធទ្រង់ទូន្មានដួងចិត្តឲ្យប្រព្រឹត្តទៅតាមសីលធម៌នោះ មិនជា ការសំខាន់សម្រាប់មនុស្សប៉ុណ្ណោះទេ ថែមទាំងធ្វើព្រះអង្គឲ្យបានចំរើន ដោយបុទ្ធិតបៈទៀតផង ព្រះពុទ្ធមានបុទ្ធិតបៈនេះជាអស្ចារ្យណាស់ ។ នេះ ជារបស់កំបាំងជាលក្ខណៈផ្ទាល់របស់ព្រះអង្គ មើលទៅតូចទេតែសំបើម ណាស់ គឺដោយបុទ្ធិអំណាចរបស់ដួងចិត្តនេះហើយជាគ្រឿងធ្វើវាចារបស់ ព្រះអង្គឲ្យមានអានុភាពឡើង ទើបព្រះអង្គធ្វើសេចក្ដីល្អ-ចំរើន ដោយព្រះ វាចាក៏បាន ឬដោយបុទ្ធិក៏បាន សឹងកើតឡើងដោយសេចក្ដីករុណាដ៏បរិ-សុទ្ធទាំងអស់ ។ ព្រះពុទ្ធត្រាស់ថា កិច្ចការរបស់ភិក្ខុ គឺការចេះអត់ ធន់ចំពោះបច្ចាមិត្តនឹងការសូមទោសគ្នាទៅវិញទៅមក ត្រង់ដែលខ្ជួនខុស តាមស្មោះត្រង់ឲ្យល្អឡើងប៉ុណ្ណោះទេ ព្រោះវិធីនេះហើយដែលនាំឲ្យ មនុស្សផងគ្នាធ្វើកិច្ចការក្នុងលោក (បានស្រួលសប្បាយ) ។ ព្រះពុទ្ធ ទ្រង់ព្រោះសាបត្រាប់ដំណាំ ពោលគឺសីលធម៌របស់ព្រះអង្គក្នុងចំការធំ

ក៏ឈ្មោះថាជាអ្នកបង្កើតសីលធម៌. ប្រកបដោយមេត្តាករុណា (ជាដំបូង) ព្រះអង្គទ្រង់បញ្ញត្តឲ្យប្រៀបរាងសេចក្ដីប្រព្រឹត្តិឥតមេត្តាចិត្តចេញ ប៉ុន្តែ មេត្តាចិត្តរបស់ព្រះអង្គជាមេត្តាប្រកបដោយហេតុផល មិនមែនចេះតែ មេត្តាទៅដោយឥតគំនិតទុះទេ ។ ឯការធ្វើសមាធិនោះ ព្រះពុទ្ធទ្រង់ធ្វើ ដែរ ដើម្បីហ្វឹកហ្វឺនដួងចិត្តឲ្យប្រព្រឹត្តទៅតាមធម្មជាតិសីលធម៌ ។

ព្រះពុទ្ធទ្រង់ទូន្មានដួងចិត្តឲ្យប្រព្រឹត្តទៅតាមសីលធម៌នោះ មិនជា ការសំខាន់សម្រាប់មនុស្សប៉ុណ្ណោះទេ ថែមទាំងធ្វើព្រះអង្គឲ្យបានចំរើន ដោយឫទ្ធិតបៈទៀតផង ព្រះពុទ្ធមានឫទ្ធិតបៈនេះជាអស្ចារ្យណាស់ ។ នេះ ជារបស់កំបាំងជាលក្ខណៈផ្ទាល់របស់ព្រះអង្គ មើលទៅតូចទេតែសំបើម ណាស់ គឺដោយឫទ្ធិអំណាចរបស់ដួងចិត្តនេះហើយជាគ្រឿងធ្វើវាចារបស់ ព្រះអង្គឲ្យមានអានុភាពឡើង ទើបព្រះអង្គធ្វើសេចក្ដីល្អ-ចំរើន ដោយព្រះ វាចាក៏បាន ឬដោយឫទ្ធិក៏បាន សឹងកើតឡើងដោយសេចក្ដីករុណាដ៏បរិ-សុទ្ធទាំងអស់ ។ ព្រះពុទ្ធត្រាស់ថា កិច្ចការរបស់ភិក្ខុ គឺការចេះអត់ ធន់ចំពោះបច្ចាមិត្តនិងការសូមទោសគ្នាទៅវិញទៅមក ត្រង់ដែលខ្លួនខុស តាមស្មោះត្រង់ឲ្យល្អឡើងប៉ុណ្ណោះទេ ព្រោះវិធីនេះហើយដែលនាំឲ្យ មនុស្សផងគ្នាធ្វើកិច្ចការក្នុងលោក (បានស្រួលសប្បាយ) ។ ព្រះពុទ្ធ ទ្រង់ព្រោះសាបត្រាប់ដំណាំ ពោលគឺសីលធម៌របស់ព្រះអង្គក្នុងចំការធំ

គឺលោកដ៏សោះសូន្យនេះ ប៉ុន្តែខ្យល់បក់យកគ្រាប់ដំណាំនោះធ្លាក់ទៅក្នុងចំការជិតខាងវិញ គឺជាចំការដែលមានរូបប្រាកដទៅវិញ ។ ដ្បិតគំនិតរបស់សាមញ្ញជនទៅឈប់ផ្អាកនៅត្រឹមណោះ ស្មើតែទៅជាទំនាស់នឹងលទ្ធិដែលបដិសេធផ្លូវលោកនោះស្រឡះ ឯឧត្តមគតិខាងសីលធម៌របស់ព្រះពុទ្ធនោះគេនាំគ្នាប្រួតកាត់យកផ្លែផ្កាទៅតាមទំនងនេះជាច្រើនសតវត្សរ៍ ។

លទ្ធិពុទ្ធៈនេះ លុះអំណើះកាលតមកទៅជាសាសនាមួយ ហើយជាសាសនាសំរាប់ប្រជាជន ទើបពុទ្ធសាសនាឃ្លាតចេញពីលទ្ធិពុទ្ធៈដែលមានប្រាកដតាមពង្សាវតារ ព្រះអង្គទ្រង់ទូន្មានឲ្យលះបង់ស្រឡះ កាត់ផ្តាច់នូវកង់កាំនៃសំសារចក្រ ដោយវិធីបួសនឹងលះបង់លោកចោលឲ្យដាច់ស្រឡះ ។ តែក្នុងវេលានេះ គេបែរជាយល់ថា មិនបាច់ចេញទៅបួសទេ មនុស្សធម្មតាក៏អាចទៅដល់ទីបំផុតទុក្ខបាន ដោយមានសេចក្តីគោរពនមស្សការចំពោះព្រះពុទ្ធទេវតា នឹងមានជំនឿជឿជាក់ក្នុងព្រះអង្គ នឹងសូមព្រះអង្គជាទីពឹង ដែលពោលមកនេះ ជាលទ្ធិរបស់ពួកយានធំ គឺមហាយាន ។

ព្រះពុទ្ធសាសនាគួរពេបថាជាមុនដំបូងបង្អស់ ក្នុងពង្សាវតារដែលនិយាយពីចិត្តគំនិតរបស់មនុស្ស ឯឧត្តមគតិនៃមេត្តាចិត្តសោតទៀត ក៏រាតទីចេញទៅកាន់វិថីធំសំបើមតាមទំនងយោបល់របស់លោក ។

នៅសីឡង់ (កោះលង្កា) ប្រទេសភូមា និងប្រទេសសៀម នៅប្រកាន់យ៉ាងស្មោះត្រង់ តាមបែបពុទ្ធសាសនាសម័យបុរាណ ។ កោះលង្កា ព្រះមហាមហិន្ទត្ថេរជាព្រះរាជបុត្រព្រះបាទធម្មាសោកចេញមកប្រកាសសាសនានៅកោះនេះ កាលពីពុទ្ធសករាជ ៣១២ ក្រោយពុទ្ធបរិនិព្វាន ។

នៅប្រទេសសៀម បានទទួលព្រះពុទ្ធសាសនាទៅពីប្រទេសខ្មែរ កាលពីពុទ្ធសករាជ ៨៧៥ ហើយចូលទៅប្រទេសភូមាកាលពីពុទ្ធសករាជ ១០៤៣ ។ សេចក្ដីកែប្រែបន្ថែមនេះឯង ជាគ្រឿងជួយគាំទ្រព្រះពុទ្ធសាសនាជាន់ដើមឲ្យគង់ទ្រង់នៅក្នុងសីឡង់ក្នុងប្រទេសភូមា និងប្រទេសសៀម នេះហើយដែលនាំឲ្យគេស្គាល់ដំឡៃសាសនា ដែលជាសាសនាសម្រាប់ប្រជាជន ។ ឥឡូវនេះគេមើលឃើញបែបពុទ្ធសាសនាជាន់ចាស់នៅក្នុងប្រទេសសីឡង់និងក្នុងប្រទេសឥណ្ឌូស៊ីននេះ (គឺភូមា, សៀម, ខ្មែរ, លាវ) តាំងពីពុទ្ធសករាជ ១៣៤៣ ក្រោយពុទ្ធបរិនិព្វានមក ពុទ្ធសាសនាផ្ដើមបាត់សាបសូន្យទៅពីប្រទេសឥណ្ឌា វៀរលែងតែខេត្តនេប៉ាលមួយនៅមានពុទ្ធសាសនា ដល់មកពុទ្ធសករាជ ២១៤៣ ទើបរលត់បាត់អស់រលីងទៅ ។

ប្រសិនបើព្រះពុទ្ធសាសនាគង់ទ្រង់នៅបានចំពោះមុខលទ្ធិសាសនា

នៅសីហ្ល័ន (កោះលង្កា) ប្រទេសភូមា និងប្រទេសសៀម នៅប្រកាន់យ៉ាងស្មោះត្រង់ តាមបែបពុទ្ធសាសនាសម័យបុរាណ ។ កោះលង្កា ព្រះមហាមហិន្ទត្ថេរជាព្រះរាជបុត្រព្រះបាទធម្មាសោកចេញមកប្រកាសសាសនានៅកោះនេះ កាលពីពុទ្ធសករាជ ៣១៤ ក្រោយពុទ្ធបរិនិព្វាន ។

នៅប្រទេសសៀម បានទទួលព្រះពុទ្ធសាសនាទៅពីប្រទេសខ្មែរ កាលពីពុទ្ធសករាជ ៨៧៥ ហើយចូលទៅប្រទេសភូមាកាលពីពុទ្ធសករាជ១០៤៣ ។ សេចក្ដីកែប្រែបន្ថែមនេះឯង ជាគ្រឿងជួយគាំទ្រព្រះពុទ្ធសាសនាជាន់ដើមឲ្យគង់ទ្រង់នៅក្នុងសីហ្ល័នក្នុងប្រទេសភូមា និងប្រទេសសៀម នេះហើយដែលនាំឲ្យគេស្គាល់ដំឡៃសាសនា ដែលជាសាសនាសម្រាប់ប្រជាជន ។ ឥឡូវនេះគេមើលឃើញបែបពុទ្ធសាសនាជាន់ចាស់នៅក្នុងប្រទេសសីហ្ល័ននិងក្នុងប្រទេសឥណ្ឌូចិននេះ (គឺភូមា, សៀម, ខ្មែរ, លាវ) តាំងពីពុទ្ធសករាជ ១៣៤៣ ក្រោយពុទ្ធបរិនិព្វានមក ពុទ្ធសាសនាផ្ដើមបាត់សាបសូន្យទៅពីប្រទេសឥណ្ឌា វៀរលែងតែខេត្តនេប៉ាល់មួយនៅមានពុទ្ធសាសនា ដល់មកពុទ្ធសករាជ ២១៤៣ ទើបរលត់បាត់អស់រលីងទៅ ។

ប្រសិនបើព្រះពុទ្ធសាសនាគង់ទ្រង់នៅបានចំពោះមុខលទ្ធិសាសនា

ព្រាហ្មណ៍ទាំងសាសនាហិណ្ឌូ ទាំងមើលឃើញលក្ខណៈដ៏ធំសំបើមរបស់ព្រះពុទ្ធសាសនា ទាំងមើលឃើញសីលធម៌របស់ពុទ្ធសាសនាខ្ពង់ខ្ពស់ជាងគេទាំងអស់ ៗ ទុកជាពុទ្ធសាសនារលត់បាត់ទៅពីឥណ្ឌៀនេះ ក៏មិនមែនថាសាសនានេះឥតដំឡៀងទ៊ុះក៏ទេដែរ ដោយហេតុប្រជាជនឥណ្ឌៀខណៈនោះងាកមុខចេញពីឫសគល់បញ្ញត្តិដែលបដិសេធផ្លូវលោក ពីព្រោះយោបល់គំនិតរបស់គេជាប់នៅទាំងសីលធម៌នេះ ធ្វើឲ្យដឹងថានៅជាប់ទាំងប្រទេសអស់នេះរហូតមកដល់សម័យឥឡូវនេះ ៗ



៣៣ — អំពីការទ្រង់ផ្លាស់ប្តូរគំនិតនៃអ្នកនេសាទត្រី

# និយាយពីពុទ្ធសាសនានៅប្រទេសជប៉ុន
# តាមសៀវភៅលោកតូមោម៉ុតស៊ុ

(តនិងចប់)

សព្វសារពើទាំងអស់ជារបស់ប្រែប្រួលមិនឋិតថេរ នឹងប្រព្រឹត្តទៅតាមសភាពដូចជាជីវិត (ការរស់នៅ) គេតែងពោលថា មនុស្សមានជីវិតតែងប្រែប្រួល ផ្លាស់ប្តូរទៅទាំងអស់ តែទុកជាដូចម្តេចក៏ដោយ សព្វសារពើទាំងអស់នោះតែងមានចំណងចងគ្នាពីមួយទៅមួយទៀតជាដរាប ៗ មនុស្សទាំងឡាយមិនមែនជាវត្ថុមានជីវិតយ៉ាងសុទ្ធសាធនឹងមានរូបកាយប៉ុណ្ណោះទេ ទាំងមិនមែនមានត្រឹមវិញ្ញាណប៉ុណ្ណោះក៏ទេដែរ គឺសព្វសារពើទាំងអស់ គេតែងមានរូបកាយនឹងមានវិញ្ញាណ ប្រព្រឹត្តទៅតាមច្បាប់តែមួយរួមគ្នា ៗ ហេតុនេះ ទើបយល់ច្បាស់នូវសេចក្តីពិតដែលនឹងកំណត់ថាមានរូបកាយក៏ពុំមែន ថាមានចិត្តវិញ្ញាណក៏ពុំមែន កាលស្គាល់ផ្លូវប្រតិបត្តិតាមច្បាប់នោះហើយនឹងបានចូលទៅជិតស្ពានក្បែរយោបល់របស់ព្រះពុទ្ធ ហើយនឹងធ្វើដំណើរទៅតាមព្រះពុទ្ធមិនខាន ដោយយល់ឃើញថា របស់ទាំងអស់ដែលមាននៅក្នុងលោក មិនថាមនុស្ស ឬរូបកាយ ឬចំណេះវិជ្ជា របស់ទាំងអស់នោះ តែងមានសេចក្តីផ្លាស់ប្តូរនឹងប្រែប្រួលទៅគ្រប់ៗខណៈ មានសេចក្តីប្រៀបដូចជាខ្លួនខ្ញុំដែលកំពុងសរសេរសៀវភៅនេះ ក៏នៅតែ

មិនមែនខ្លួនខ្ញុំទេដែលកំពុងគិតតែរឿងមួយនេះដែរ ខ្ញុំមិនមានឈប់ឈរទេ គោងទៅតាមកំឡាំងអាកាស តាមភ្លៀង តាមខ្យល់ និងកំឡាំងកិច្ចការសព្វសារពើដទៃទៀត ដែលនាំខ្ញុំឲ្យប្រព្រឹត្តទៅតាមគ្រោះថ្នាក់របស់ខ្លួនតែរៀងរាល់ថ្ងៃ ៗ របស់ទាំងអស់តែងប្រព្រឹត្តទៅនិងផ្លាស់ប្តូរទៅតាមកាលវេលាដែលកន្លងទៅហើយ និងទៅតាមហេតុមុខគួរស្ងប់ស្ងៀងនឹងកំឡាំងយ៉ាងធំសំបើមនេះទាំងអស់ ៗ ទុកជាមានឫទ្ធិធំសំបើមយ៉ាងណាក្តី បំណងរបស់មនុស្សលោកមានទៅយ៉ាងណាក្តី ក៏នៅតែមិនអាចទប់ទល់នឹងច្បាប់ធម្មជាតិនេះបានឡើយ ៗ ធម្មជាតិក្តី មនុស្សក្តី សមាគមរបស់មនុស្សក្តី របស់ទាំងអស់សុទ្ធតែប្រែប្រួល និងផ្លាស់ប្តូរពងទៅតាមច្បាប់បញ្ញត្តិរបស់សភាពមិនទៀងទាត់ឋិតថេរ ដែលមានប្រចាំសកលចក្រវាឡ ព្រោះព្រះពុទ្ធទ្រង់ត្រាស់ឲ្យមនុស្សទាំងឡាយដឹងច្បាស់នូវសេចក្តីពិតនេះ ហើយត្រូវឲ្យខំប្រឹងរកការពិតការមែន ប្រកបដោយហេតុផលតែម្យ៉ាង ៗ ប្រសិនបើបុគ្គលនីមួយៗ ចង់បានសេចក្តីសុខគ្មានទីបំផុតដោយចិត្តរំលោភទាំងខ្លាក់ និងភ្លេចបញ្ញត្តិនៃអាការដ៏ប្រែប្រួលមិនឋិតថេរគេទីបំផុតពុំឃើញហើយ មុខជានឹងនាំឲ្យខូចខាតកិច្ចការដ៏ស្ងប់ស្ងាត់មិនខាន ៗ ពួកអ្នកឯណាខំប្រឹងព្យាយាមធ្វើតាមបញ្ញត្តិនេះ ទើបអាចនឹងមើលឃើញផ្លូវខាងមុខយ៉ាងច្បាស់លាស់បាន ៗ

មិនមែនខ្លួនខ្ញុំទេដែលកំពុងគិតតែរឿងមួយនេះដែរ ខ្ញុំមិនមានឈប់ឈរទេ គោងទៅតាមកំឡាំងអាកាស តាមភ្លៀង តាមខ្យល់ និងកំឡាំងកិច្ចការសព្វសារពើដទៃទៀត ដែលនាំខ្ញុំឲ្យប្រព្រឹត្តទៅតាមគ្រោះថ្នាក់របស់ខ្លួនតែរៀងរាល់ថ្ងៃ ៗ របស់ទាំងអស់តែងប្រព្រឹត្តទៅនិងផ្លាស់ប្តូរទៅតាមកាលវេលាដែលកន្លងទៅហើយ និងទៅតាមហេតុមុខគួរស្ងប់ស្ងែងនិងកំ-ឡាំងយ៉ាងធំសំបើមនេះទាំងអស់ ៗ ទុកជាមានឫទ្ធិធំសំបើមយ៉ាងណាក្តី បំណងរបស់មនុស្សលោកមាននៅយ៉ាងណាក្តី ក៏នៅតែមិនអាចទប់ទល់និងច្បាប់ធម្មជាតិនេះបានឡើយ ៗ ធម្មជាតិក្តី មនុស្សក្តី សមាគមរបស់មនុស្សក្តី របស់ទាំងអស់សុទ្ធតែប្រែប្រួល និងផ្លាស់ប្តូរទៅតាមច្បាប់បញ្ញត្តិរបស់សភាពមិនទៀងទាត់ឋិតថេរ ដែលមានប្រចាំសកលចក្រវាឡ ព្រោះព្រះពុទ្ធទ្រង់ត្រូវការឲ្យមនុស្សទាំងឡាយដឹងច្បាស់នូវសេចក្តីពិតនេះ ហើយត្រូវឲ្យខំប្រឹងរកការពិតការមែន ប្រកបដោយហេតុផលតែម្យ៉ាង ៗ ប្រសិនបើបុគ្គលណាមួយ ៗ ចង់បានសេចក្តីសុខគ្មានទីបំផុតដោយចិត្តរំលោភទាំងខ្លាក់ និងភ្លេចបញ្ញត្តិនៃអាការដ៏ប្រែប្រួលមិនឋិតថេររកទីបំផុតពុំឃើញហើយ មុខជានឹងនាំឲ្យខូចខាតកិច្ចការដ៏ស្ងប់ស្ងាត់មិនខាន ៗ ពួកអ្នកឯណាខំប្រឹងព្យាយាមធ្វើតាមបញ្ញត្តិនេះ ទើបអាចនឹងមើលឃើញផ្លូវខាងមុខយ៉ាងច្បាស់លាស់បាន ៗ

សូម្បីមនុស្សទាំងឡាយដឹងថាមនុស្សសត្វទាំងអស់តែងតែប្រែប្រួល និងស្លាប់ទៅជាប្រាកដក្តី ក៏គេនៅតែចង់ឲ្យឋានៈរបស់គេនិងកិច្ចការរបស់គេប្រកបដោយសេចក្តីខ្ជាប់ខ្ជួននិងទៀងទាត់ជាប់ជានិច្ច ។

ព្រះពុទ្ធទ្រង់ធ្វើឲ្យបរមត្ថវិជ្ជានៃអាការមិនទៀងទាត់ឋិតថេរនេះ មានសេចក្តីចំរើនឡើងច្រើន ប៉ុន្តែក្រោយព្រះអង្គបរិនិព្វានទៅ ពួកពុទ្ធបរិសទ្យជាតិឥណ្ឌានាំគ្នាបំភ្លេចចោលធម៌ដែលនិយាយពីអាការមិនឋិតថេរនេះអស់ ។

ឯពួកយើងជាមនុស្សសម័យថ្មី ត្រូវតែសើរើឫទ្ធិអំណាចជាគោលដើមរបស់ព្រះពុទ្ធសាសនាឡើងវិញ ត្រង់ដែលនិយាយពីបរមត្ថវិជ្ជាបែកខាងអសារធម៌នេះ ។ ពួកពុទ្ធសាសនិកជនខ្លួនទៅគិតតែកែខៃឋានៈរបស់ខ្លួនឲ្យកាន់តែស្រួលសប្បាយលើសលុបឡើង ហើយបានសំឡឹងមើលប្រស្នាជំនុំជនជារឿយៗដែរ តែទុកជាថ្នាក់ទី ២ ។ ពួកពុទ្ធសាសនិកជនឥណ្ឌានោះជាវេលាយូរណាស់មកហើយ គេគិតតែប្រកាន់យ៉ាងម៉ឺងម៉ាត់ចំពោះសាសនាសម្រាប់ពួកខ្លួននីមួយៗ និងកិច្ចការរបស់មនុស្សផងគ្នា តែបែរជាមិនយកចិត្តទុកដាក់នឹងកិច្ចការសមាគមក្នុងពិភពលោកនេះឡើយ ។

ប្រសិនបើមនុស្សទាំងឡាយ ដឹងស្គាល់អំពើអាក្រក់និងល្អដែលមាននៅសព្វគ្រប់ក្នុងរាងមនុស្សលោកនិងបុគ្គលនីមួយៗ ដូច្នេះហើយគេនាំគ្នា

ប្រព្រឹត្តតាមមនោគតិ ឬតាមទំនងធម៌ដែលមានក្នុងខ្លួនមនុស្សម្នាក់ៗ និងក្នុងសមាគម មុខជានឹងកើតជាលទ្ធិមួយមានតែសេចក្តីក្រេមក្រាន្តនិងសេចក្តីថ្លៃថ្លា ។ ឯសមាគមនៅសម័យយើងសព្វថ្ងៃនេះ ក៏នៅតែមានមនុស្សជាច្រើនដែលគិតតែស្វែងរកប្រយោជន៍ផ្ទាល់ខ្លួន និងសេចក្តីហ៊ឺហាសប្បាយរបស់ខ្លួន មិនគិតធ្វើសេចក្តីចំរើនដល់អ្នកដទៃទៀតឡើយ ។ បុគ្គលណាដែលចង់បានផលប្រយោជន៍ចំណេញ ឬទាមទារយកផលា-និសង្សអំពីការងាររបស់ខ្លួន សត្វបែបនេះមិនចាត់ថាជាអ្នកមានសទ្ធាដើម្បីព្រះពុទ្ធឡើយ ។

ឯសទ្ធាដ៏ខ្ពង់ខ្ពស់នោះគោងតែគិតកំចាត់បង់នូវតណ្ហា រាគៈ និងមច្ឆរិ-យធម៌ចេញឲ្យអស់ ។ ការនឹកសង្ឃឹមសុំជំនួយពីព្រះពុទ្ធឥតប្រតិបត្តិតាមបរមត្ថធម៌របស់ព្រះអង្គសោះនោះមិនមែនជាសុចរិតទេ ។

ព្រះពុទ្ធត្រាស់ថា ព្រះនិព្វានមិនមែនជាទីបំផុតនៃជីវិតយើងទេ ហើយឧត្តមគតិរបស់មនុស្សលោក មិនមែនជាតួមរណៈរបស់តណ្ហា ឬជាទីបំផុតកិច្ចការផ្សេងៗទេ ព្រះអង្គនឹងមិនស្វែងរកឈានសមាបត្តិ ដោយវិធីបដិបត្តិការនានាយ៉ាងស្ងាត់ៗ និងនៅស្ងៀមនោះទេ របស់ដែលព្រះអង្គត្រូវការចង់បាននោះ គឺធម៌ជាគ្រឿងរំលត់កម្មរបស់មនុស្សលោក រលត់ទាំងកម្មរលត់ទាំងការអន្ទោល ៗ ពាក្យថានិព្វានៈនេះ ព្រះពុទ្ធជា

ប្រព្រឹត្តតាមមនោគតិ ឬតាមទំនងធម៌ដែលមានក្នុងខ្លួនមនុស្សម្នាក់ៗ និងក្នុងសមាគម មុខជានឹងកើតជាលទ្ធិមួយមានតែសេចក្ដីក្សេមក្សាន្តនឹងសេចក្ដីថ្លៃថ្លា ។ ឯសមាគមនៅសម័យយើងសព្វថ្ងៃនេះ ក៏នៅតែមានមនុស្សជាច្រើនដែលគិតតែស្វែងរកប្រយោជន៍ផ្ទាល់ខ្លួន និងសេចក្ដីហ៊ឺហាសប្បាយរបស់ខ្លួន មិនគិតធ្វើសេចក្ដីចំរើនដល់អ្នកដទៃទៀតឡើយ ។ បុគ្គលណាដែលចង់បានផលប្រយោជន៍ចំណេញ ឬតាមការយកផលានិសង្សអំពីការងាររបស់ខ្លួន សត្វាបែបនេះមិនបាត់ថាជាអ្នកមានសទ្ធាដើម្បីព្រះពុទ្ធឡើយ ។

ឯសទ្ធាដ៏ខ្ពង់ខ្ពស់នោះតោងតែគិតកំចាត់បង់នូវតណ្ហា រាគៈ និងមច្ឆរិយធម៌ចេញឲ្យអស់ ។ ការទឹកសង្ឃឹមសុំជំនួយពីព្រះពុទ្ធឥតប្រតិបត្តិតាមបរមត្ថធម៌របស់ព្រះអង្គសោះនោះមិនមែនជាសុចរិតទេ ។

